លេខ៖ D193/33

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារបកប្រែ
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 14-Aug-2015, 11:25
CMS/CFO: Sann Rada

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥**

ភាសា ៖ **ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើ D167, D193/7, D193/17, D193/31 និង D193/32 របស់ សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បញ្ចូលឯកសារសម្រាប់សំណុំរឿង ០០២

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា** **អង្គជំនុំជម្រះសាលាដំបូង**

ជា លាង
Nicholas KOUMJIAN

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដាក់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[2]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[3]។

**បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ **ឆ្នាំ ១៩៥៦ អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩** និង**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

**បានឃើញ**វិធាន ៥៣, ៥៦, ៧២, ៨០ និង៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)។

**បានឃើញ** ករណីខ្វែងយោបល់គ្នាចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

---

[1] សំណុំរឿង០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០០៨។ សំណុំរឿង០០៤ ឯកសារD1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[2] សំណុំរឿង០០៤ ឯកសារD65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

[3] សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

**បានឃើញ** អនុស្សរណៈចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ ពីប្រធានអង្គជំនុំជម្រះសាលាដំបូង ស្តីពី ព័ត៌មានទាក់ទិននឹងចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលអាចពាក់ព័ន្ធនឹង សំណុំរឿង ០០២[4]។

**បានឃើញ** *ដីកាសម្រេចលើសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០២* ដាក់នៅថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០១៤ (“ដីកាសម្រេចថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤”)[5]។

**បានឃើញ** *ដីកាសម្រេចកែប្រែដីកាសម្រេច D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15 និង D193/16 លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២/០២* ចេញនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥(“ដីកាកែប្រែដីកាសម្រេច”)[6]។

**បានឃើញ** *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសម្រាប់សំណុំរឿង ០០២-សំណើ D193, D193/7 និង D193/23* ចេញនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (“ដីកាសម្រេចថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥”)[7]។

**បានពិចារណា** *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបង្ហាញឯកសារនៅក្នុងសំណុំរឿង* ដាក់ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣(“D167”)[8]។

---

[4]សំណុំរឿង ០០២ ឯកសារ E127/7/1 *ព័ត៌មានទាក់ទិននឹងចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២* ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣។

[5]សំណុំរឿង០០៤ឯកសារD193/4*ដីកាសម្រេចលើសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១ នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០២* ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

[6]សំណុំរឿង០០៤ ឯកសារD193/19 *ដីកាសម្រេចកែប្រែដីកាសម្រេច D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15 និងD193/16 លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៅក្នុងសំណុំ រឿង ០០២/០២* ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥។

[7]សំណុំរឿង០០៤ ឯកសារD193/24 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសម្រាប់សំណុំរឿង ០០២-សំណើ D193, D193/7 និង D193/23* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥។

[8]សំណុំរឿង០០៤ ឯកសារD167 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣។

**បានពិចារណា** *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង ០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១* ដាក់នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤("D193/7")[9]។

**បានពិចារណា** *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយនៃសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង០០២/០២* ដាក់ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ("D193/17")[10]។

**បានពិចារណា** *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី និងរបាយការណ៍របស់ផ្នែកគាំពារជនរងគ្រោះនៃសំណុំរឿង ០០៤ចូលទៅក្នុងសំណុំរឿង ០០២* ដាក់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ("D193/31")[11]។

**បានពិចារណា** *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០៤ និងរបាយការណ៍របស់ផ្នែកគាំពារជនរងគ្រោះដែលទាក់ទងនឹងប្រជាជនចាម ចូលទៅក្នុងសំណុំរឿង ០០២* ដាក់ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១៥ ("D193/32")[12]។

---

[9] សំណុំរឿង០០៤ ឯកសារD193/7 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង ០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១* ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤។

[10] សំណុំរឿង០០៤ ឯកសារD193/17 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុ នៃការស្តាប់ ចម្លើយនៃសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង០០២/០២* ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤។

[11] សំណុំរឿង០០៤ ឯកសារD193/31 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងរបាយការណ៍របស់ផ្នែកគាំពារជនរងគ្រោះនៃសំណុំរឿង ០០៤ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥។

[12] សំណុំរឿង០០៤ ឯកសារD193/32 *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០៤ និងរបាយការណ៍របស់ផ្នែកគាំពារជនរងគ្រោះដែលទាក់ទងនឹងប្រជាជនចាម ចូលទៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១៥។

## ប្រវត្តិនីតិវិធី

១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អន្តរជាតិ") រំឭកឡើងវិញ និងបញ្ចូលការយោងលើប្រវត្តិនីតិវិធីដែលបានសង្ខេបនៅក្នុងកថាខណ្ឌ ១ ដល់ ៧ នៃដីកាសម្រេចថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

២. នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានចេញ *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២*("ដីកាសម្រេចថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៤")ដោយក្នុងនោះគាត់បានបដិសេធសំណើ D193 របស់សហព្រះរាជអាជ្ញាអន្តរជាតិ("ស.ព.អ") ដែលសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន២៣១ ដោយគាត់បានកត់សម្គាល់ដូចជា"មិនទាន់មានការកំណត់កាលបរិច្ឆេទច្បាស់លាស់ដើម្បីចាប់ផ្តើមសវនាការនៅក្នុងសំណុំរឿង០០២/០២"[13]។ ស.ច.ស.អន្តរជាតិ នៅតែទទួលយកសំណើ D193 រហូតដល់ពេលដែលការបង្ហាញកំណត់ហេតុស្តាប់ចម្លើយនឹងមិនប៉ះពាល់ដល់ការស៊ើបអង្កេតដែលកំពុងបន្តដំណើរការ ដោយនៅ ពេលនោះគាត់នឹងអនុញ្ញាតឱ្យ ស.ព.អ ស្នើសុំទទួលយកកំណត់ហេតុទាំងនោះដាក់ចូលក្នុងសំណុំរឿង ០០២/០២[14]។

៣. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានអនុញ្ញាតតាមសំណើ D193/2 និងសំណើ D193/3 សុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ២៦ នាក់[15]។ ស.ច.ស.អន្តរជាតិ បានបង្កើតឱ្យមានការដាក់កំហិត និងទម្រង់បែបបទមួយចំនួនក្នុងការ

---

[13]សំណុំរឿង០០៤ ឯកសារD193/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០២* ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ១១ និង ១៧។

[14]ដីកាសម្រេចថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ១២ និង ១៧។

[15]ដីកាសម្រេចថ្ងៃទី១៤ ខែតុលា កថាខណ្ឌ ១៩-២០។ សំណុំរឿង០០៤ ឯកសារD193/2 *សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២* ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤ ("D193/2")។ សំណុំរឿង០០៤ ឯកសារ D193/3 *សំណើ បន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២* ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៤ ("D193/3")។

បង្ហាញកំណត់ហេតុទាំងនោះជូនទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនានានៅក្នុងសំណុំរឿង០០២/០២[16]។

៤. បន្ទាប់ពីមានសំណើពីអង្គជំនុំជម្រះសាលាដំបូងសុំកែប្រែលក្ខខណ្ឌក្នុងការបង្ហាញឯកសារជូនទៅភាគីនានានៅក្នុងសំណុំរឿង ០០២/២ មក ស.ច.ស.អន្តរជាតិ បានចេញដីកាកែប្រែ លក្ខខណ្ឌ និងទម្រង់បែបបទក្នុងការបង្ហាញឯកសារនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥[17]។

**សារណា**

៥. នៅក្នុងសំណើD167 ស.ព.អ ធ្លាប់បានស្នើសុំដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន១៤ ដែល ស.ព.អ អះអាងថាពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីជំនុំជម្រះដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០២/០២។ ស.ច.ស.អន្តរជាតិ បានយល់ព្រមឲ្យបង្ហាញឯកសារទាំង ១៤ ប៉ុន្តែ ឯកសារចំនួន ៣ ត្រូវបានដាក់បង្ហាញដោយមានការកោសលុប[18]។

៦. នៅក្នុងសំណើD193/7 និង D193/17 ស.ព.អ ស្នើសុំដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែល ស.ព.អ អះអាងថាពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីជំនុំជម្រះដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០២/០២។ ស.ច.ស.អន្តរជាតិ កត់សម្គាល់ថាក្នុងចំណោមឯកសារសរុបដែលបានស្នើដោយ ស.ព.អ រវាងសំណើ D193/7 និងសំណើ D193/17 មានតែឯកសារចំនួន ១៥ ប៉ុណ្ណោះដែលរហូតមកដល់ពេលនេះមិនបានត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ឬក៏ត្រូវបានបដិសេធមិនឲ្យដាក់បង្ហាញជាអចិន្ត្រៃយ៍។

---

[16]ដីកាសម្រេចថ្ងៃទី១៤ ខែតុលា កថាខណ្ឌ ១៩-២០ និង ២៣។

[17]សំណុំរឿង ០០៤ ឯកសារ D193/18 *សំណើសុំកែប្រែការកំហិតផ្សេងៗពាក់ព័ន្ធទៅនឹងការដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤* ដាក់ដោយអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤ ឯកសារ D193/19 *ដីកាសម្រេចកែប្រែដីកាសម្រេច D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15 និងD193/16 លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង០០២/០២* ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥។

[18]សំណុំរឿង០០៤ ឯកសារ D167/1 *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបង្ហាញឯកសារនៅក្នុងសំណុំរឿង០០២* ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ៦ ("ដីកាសម្រេចថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៣")។

៧. នៅក្នុងសំណើD193/31 ស.ព.អ ស្នើសុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២៥៨ ឯកសារ និងរបាយការណ៍ចំនួន ២៤៨ របស់អង្គភាពគាំពារជនរងគ្រោះស្ដីពីអ្នកដាក់ពាក្យសុំជាដើមបណ្ដឹងរដ្ឋប្បវេណី ដែល ស.ព.អ អះអាងថាពាក់ព័ន្ធនឹងកិច្ចដំណើរការជំនុំជម្រះដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង០០២/០២។ ស.ព.អ អះអាងថា សំណើនេះគឺជាសំណើបន្ទាន់ ពីព្រោះថា ឯកសារដែលបានស្នើគឺពាក់ព័ន្ធនឹងវគ្គសវនាការស្ដីពីទំនប់ត្រពាំងថ្ម ដែលបច្ចុប្បន្ននេះកំពុងតែធ្វើសវនាការដោយអង្គជំនុំជម្រះសាលាដំបូង[19]។

៨. នៅក្នុងសំណើD193/32 ស.ព.អ ស្នើសុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣១ ឯកសារ និងរបាយការណ៍ចំនួន ២៤ របស់អង្គភាពគាំពារជនរងគ្រោះស្ដីពីអ្នកដាក់ពាក្យសុំជាដើមបណ្ដឹងរដ្ឋប្បវេណី ដែល ស.ព.អ អះអាងថាពាក់ព័ន្ធនឹងកិច្ចដំណើរការជំនុំជម្រះដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង០០២/០២។ ស.ព.អ អះអាងថា សំណើនេះគឺជាសំណើបន្ទាន់ ពីព្រោះថា ឯកសារដែលបានស្នើគឺពាក់ព័ន្ធនឹងវគ្គសវនាការស្ដីពីប្រជាជនចាម ជាក្រុមមុខសញ្ញា ដែលសវនាការនេះគ្រោងនឹងចាប់ផ្ដើមនៅខែ កញ្ញា ឆ្នាំ ២០១៥ ខាងមុខនេះ[20]។

## ពិភាក្សា

៩. ស.ច.ស.អន្តរជាតិ រំឭកឡើងវិញអំពីច្បាប់ជាធរមានដែលបានសង្ខេបនៅក្នុងកថាខណ្ឌ ១៥ ដល់ ១៨ នៅក្នុងដីកាសម្រេចថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០១៤ ហើយយោងលើច្បាប់ទាំងនោះ។

១០. យោងលើសំណើ D193/7 និង D193/17 ស.ច.ស.អន្តរជាតិ រំឭកឡើងវិញអំពីការពិចារណានៅក្នុងដីកាសម្រេចថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ហើយដោយដឹងថាការពិចារណាទាំងនេះជាប់ពាក់ព័ន្ធនឹងសំណើបច្ចុប្បន្ននេះ ស.ច.ស.អន្តរជាតិ ក៏បញ្ចូលការពិចារណាទាំងនេះតាមរយៈការលើកយោង[21]។ ស.ច.ស.អន្តរជាតិ ជឿជាក់ថា

[19]ឯកសារ D193/31 កថាខណ្ឌ ១-២។

[20]ឯកសារ D193/32 កថាខណ្ឌ ១-២។

[21]ដីកាសម្រេចថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៩។

ការផ្លាស់ប្តូរកាលៈទេសៈចាប់តាំងពីមានដីកាសម្រេចថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ មក គឺតម្រូវឱ្យដាក់បង្ហាញឯកសារដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក និង ខ។

១១. យោងលើសំណើ D167 ស.ច.ស.អន្តរជាតិ ជឿជាក់ថា ការផ្លាស់ប្តូរកាលៈទេសៈចាប់តាំងពីមានដីកាសម្រេចថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៣ មក គឺតម្រូវឱ្យដាក់បង្ហាញឯកសារចំនួន ២ ដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ គ ដោយគ្មានការកោសលុប។ ឯកសារទាំងនេះធ្លាប់ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញតែក្នុងទម្រង់ជាឯកសារកោសលុប។

១២. ឧបសម្ព័ន្ធ ក អនុញ្ញាតឱ្យដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយដែលនៅសល់ចំនួន ១៤ ឬឯកសារផ្សេងទៀតដែលបានស្នើនៅក្នុងសំណើ D193/7។

១៣. ឧបសម្ព័ន្ធ ខ អនុញ្ញាតឱ្យដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយដែលនៅសល់មួយដែលបានស្នើនៅក្នុងសំណើ D193/17។

១៤. ឧបសម្ព័ន្ធ គ អនុញ្ញាតឱ្យដាក់បង្ហាញដោយគ្មានការកោសលុបនូវឯកសារចំនួន ២ ដែលបាន ស្នើនៅក្នុងសំណើ D167។

១៥. ឧបសម្ព័ន្ធ ឃ អនុញ្ញាតឱ្យដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥៥ ឯកសារ និងរបាយការណ៍ចំនួន ២៤៥ របស់អង្គភាពគាំពារជនរងគ្រោះស្តីពីអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើនៅក្នុងសំណើ D193/31។ ស.ច.ស. អន្តរជាតិ នឹងនៅតែទទួលពិនិត្យសំណើនេះ ទាក់ទងនឹងអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ នាក់ ដែលការដាក់បង្ហាញឯកសាររបស់ពួកគាត់អាចប៉ះពាល់ដល់កិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៤ នៅក្នុងដំណាក់កាលនេះ គឺ៖

(i) តាំង ផាត(D5/1226, D5/1226/1)

(ii) [redacted]

(iii) យិត សារ៉ី (D5/1102, D5/1102/1)។

១៦. ឧបសម្ព័ន្ធ ង អនុញ្ញាតឱ្យដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចំនួន ៣១ ឯកសារ និងរបាយការណ៍ទាំងអស់ចំនួន ២៤ របស់អង្គភាពគាំពារជនរងគ្រោះស្តីពីអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើនៅក្នុងសំណើ D193/32។

១៧. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ MARK B. HARMON ៖**

១៨. **អនុញ្ញាតឲ្យ**បង្ហាញឯកសារនានាដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក យោងលើសំណើ D193/7 ឧបសម្ព័ន្ធ ខ យោងលើសំណើ D193/17 ឧបសម្ព័ន្ធ គ សម្រាប់ឯកសារគ្មានការកោសលុបយោងលើសំណើ D167 ឧបសម្ព័ន្ធ ឃ យោងលើសំណើ D193/31 និង ឧបសម្ព័ន្ធ ង យោងលើសំណើ D193/32 ជូនទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនានានៅក្នុងសំណុំរឿង ០០២/០២។ ដោយសារលក្ខណៈសម្ងាត់ និងរសើបនៃការស៊ើបអង្កេតដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៤ ទើបការបង្ហាញនេះត្រូវបានអនុញ្ញាតក្នុងទម្រង់បែបបទ និងមានការដាក់កំហិតដូចខាងក្រោម៖

(ក) រាល់សម្ភារៈទាំងអស់ដែលផ្តល់ជូនពីសំណុំរឿង ០០៤ ត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

(ខ) សម្ភារៈដែលអនុញ្ញាតឲ្យបង្ហាញ ត្រូវតែបំលែងតាមអេឡិចត្រូនិកទៅជាទម្រង់មួយដែលឲ្យមានសញ្ញា(watermark)មិនអាចលុបជ្រះជាអក្សរក្រោម(sub-script)នៅលើទំព័រនីមួយៗនៃគ្រប់ឯកសារទាំងអស់សម្រាប់ភាគីទទួលនីមួយៗ។

(គ) កំណត់ហេតុនៃការស្តាប់ចម្លើយដែលអនុញ្ញាតឲ្យបង្ហាញ ត្រូវតែផ្តល់ជូនទៅក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ ខៀវ សំផន ("មេធាវីប្រចាំការ") និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈសំណៅ អេឡិចត្រូនិចដែលមានសញ្ញា watermark សម្រាប់ភាគីនីមួយៗ។

(ឃ) ក.ស.ព ត្រូវតែបង្ហាញឯកសារក្នុងរបៀបមួយដែលភាគីនីមួយៗ អាចចូលពិនិត្យមើលបានតែតាមរយៈសំណៅអេឡិចត្រូនិកដែលមានសញ្ញា waterwmark សម្រាប់ភាគីនីមួយៗតែប៉ុណ្ណោះ។

(ង) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ឲ្យទៅតែសមាជិកណានៅក្នុងក្រុមការងាររបស់ខ្លួនដែលទទួលបានការងារជាផ្លូវការតាមវិធានផ្ទៃក្នុង ២២(៥)និង១២*ស្ទួនពីរ*(៤) ព្រមទាំងកម្មសិក្សាការីដែលទទួលបានការចាត់តាំងផ្លូវការតែប៉ុណ្ណោះ។

(ច) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថត ចម្លងសំណៅថតចម្លងនៃឯកសារដើមក្រៅពីគោលបំណងប្រើប្រាស់ផ្ទៃក្នុងដែលបាន ផ្តល់ជូនខ្លួនពីសមាជិកក្រុមការងាររបស់ខ្លួន ដែលត្រូវបានណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់។

(ឆ) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសំណៅថតចម្លងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង គឺត្រូវរក្សាទុកក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

(ជ) ក្នុងករណីដែលសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ សម្ភារៈនេះត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

(ឈ) គ្មានសម្ភារៈណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវផ្សព្វផ្សាយឲ្យហួសពីអ្វីដែលបានកំណត់យ៉ាងច្បាស់នៅក្នុងនេះឡើយ។

(ញ) គ្មានសម្ភារៈណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះត្រូវផ្សព្វផ្សាយដល់សាធារណជន ក្នុងទម្រង់ណាមួយ ឬតាមរយៈរូបភាពណាមួយនៃប្រព័ន្ធផ្សព្វផ្សាយអ្វីឡើយ។

(ដ) ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ គាត់ត្រូវចាត់វិធានការទាំងអស់ភ្លាមៗ ដើម្បីរក្សាសុវត្ថិភាពសំណៅនោះ និងប្រគល់សំណៅនោះជូន ស.ច.ស វិញ។

(ឋ) ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កំហិតទាំងនេះ គាត់ត្រូវរាយការណ៍ការរំលោភបំពានបែបនេះជូន ស.ច.ស។

១៩. **បញ្ជាក់** ថា សម្រាប់គោលបំណងនៃដីកាសម្រេចនេះ ពាក្យថា "សាធារណជន" គឺមានន័យរាប់បញ្ចូលទាំងជនគ្រប់រូប រដ្ឋាភិបាល អង្គការ ស្ថាប័ន កូនក្តី សមាគម និងក្រុមមនុស្សគ្រប់ប្រភេទទាំងអស់ ដែលមិនមែនជាចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង បុគ្គលិកផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា តំណាងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ បុគ្គលិកណាដែលទទួលបានការងារជាផ្លូវការតាមវិធានផ្ទៃក្នុង ២២(៥) និង ១២*ស្ទួនពីរ*(៤) ហើយទទួលបានការអនុញ្ញាតពីមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់។ ពាក្យថា "សាធារណជន" ក៏រាប់បញ្ចូលដោយមិនកំណត់ផងដែរទាំងសមាជិកគ្រួសាររបស់ជនជាប់ចោទ មិត្តភក្តិ សហការី ជនសង្ស័យ មេធាវីការពារក្តី និងសមាជិកបុគ្គលិករបស់ខ្លួននៅក្នុងរឿងក្តី ឬកិច្ចដំណើរការនីតិវិធីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន។

២០. **បង្គាប់**ថា លក្ខខណ្ឌ និងការដាក់កំហិតខាងលើ ត្រូវនៅជាធរមានរហូតដល់ពេលដែល ស.ច.ស ចេញដីកាច្បាស់លាស់ណាមួយដែលផ្ទុយពីលក្ខខណ្ឌ និងការដាក់កំហិតទាំងនោះ ឬក៏នៅពេលណាដែលការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៤ ត្រូវបានចាត់ទុកថាបានបិទរួចហើយ។

២១. **ស្នើ** អង្គជំនុំជម្រះសាលាដំបូង ធានាថា ភាគីទាំងអស់គោរពតាមដីកាសម្រេចនេះ។

២២. **នៅតែទទួលពិនិត្យ**សំណើD193/31ទាក់ទងនឹងសាក្សីតាំងផាត(D5/1226,D5/1226/1) [redacted] និងសាក្សី(iii)យិត សារ៉ី(D5/1102, D5/1102/1)។

ភ្នំពេញ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥

**ចៅក្រម Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**